**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*
លេខ ២១៣ ព.ណ ប.ល.ប្រក

# ប្រកាស
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** :

នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស មានតួនាទី និងភារកិច្ចដូចតទៅ៖

- កសាងផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ក្រសួង
- ធ្វើសហប្រតិបត្តិការលើវិស័យស្ថិតិពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- ទទួលបន្ទុកជាមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មរបស់ក្រសួង
- ផ្សព្វផ្សាយទិន្នន័យស្ថិតិពាណិជ្ជកម្មស្តីពី ស្ថានភាពនៃការវិវត្តលើផ្នែកពាណិជ្ជកម្មក្នុង និងក្រៅប្រទេស



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

- ចងក្រង និងណែនាំអនុវត្ត ដោយឯកភាពតាមចំណាត់ថ្នាក់ព័ត៌មានពាណិជ្ជកម្ម
- សិក្សាស្រាវជ្រាវ ប្រមូល និងវិភាគព័ត៌មានតាមលំដាប់ ដើម្បីបង្កើតតារាងនៃការប្រែប្រួលថ្លៃ
- សិក្សា វិភាគ និងតាមដានទិន្នន័យថ្លៃទំនិញលើទីផ្សារអន្តរជាតិ
- រៀបចំផ្សព្វផ្សាយទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ និងស្ថិតិពាណិជ្ជកម្ម
- បោះពុម្ពផ្សាយព្រឹត្តិបត្ររបស់ក្រសួង
- រៀបចំ និងគ្រប់គ្រងបណ្តាញព័ត៌មានវិទ្យា និងគេហទំព័ររបស់ក្រសួង
- ផ្សព្វផ្សាយលើគេហទំព័រពីទិន្នន័យ និងស្ថិតិពាណិជ្ជកម្ម
- លើកគម្រោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ ផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ២** :

នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

**ប្រការ ៣** :

នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម មានការិយាល័យចំណុះចំនួន ០៥ គឺ៖

១- ការិយាល័យផែនការពាណិជ្ជកម្ម

២- ការិយាល័យរដ្ឋបាលទូទៅ

៣- ការិយាល័យសរុបស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

៤- ការិយាល័យបច្ចេកទេសព័ត៌មានវិទ្យា

៥- ការិយាល័យព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មាន

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៤** :

ការិយាល័យផែនការពាណិជ្ជកម្ម មានភារកិច្ច៖

- កសាងផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ក្រសួង ដោយសហការជាមួយនឹងអគ្គនាយកដ្ឋានពាក់ព័ន្ធ
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការរួមនៃវិស័យពាណិជ្ជកម្ម
- សហការជាមួយបណ្តាអង្គភាពពាក់ព័ន្ធ ដើម្បីទទួលចងក្រង និងផ្តល់ទិន្នន័យសម្រាប់ការងារផែនការ

- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៥** :

ការិយាល័យរដ្ឋបាលទូទៅ មានភារកិច្ចៈ

- ការងាររដ្ឋបាលទូទៅក្នុងនាយកដ្ឋាន
- រៀបចំសំណុំឯកសារសម្រាប់ការគ្រប់គ្រងមន្ត្រីក្នុងនាយកដ្ឋាន
- គ្រប់គ្រងអចលទ្រព្យ និងចលនទ្រព្យក្នុងនាយកដ្ឋាន
- លើកគម្រោងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីជំនាញផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៦** :

ការិយាល័យសរុបស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម មានភារកិច្ចៈ

- រៀបចំបង្កើតតារាងគំរូលំអិតផ្សេងៗ ដើម្បីជាមូលដ្ឋានឲ្យនាយកដ្ឋាន និងមន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត
- ចងក្រង និងណែនាំអនុវត្ត ដោយឯកភាពតាមចំណាត់ថ្នាក់ព័ត៌មានពាណិជ្ជកម្ម
- សិក្សាស្រាវជ្រាវ ប្រមូល និងវិភាគព័ត៌មានតាមលំដាប់ ដើម្បីបង្កើតតារាងនៃការប្រែប្រួលថ្លៃ
- សិក្សា វិភាគ និងតាមដានទិន្នន័យថ្លៃទំនិញលើទីផ្សារអន្តរជាតិ
- រៀបចំការស្រាវជ្រាវ វិភាគឃ្លាំមើលទីផ្សារ និងលំហូរផលិតផលកម្ពុជា
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៧** :

ការិយាល័យបច្ចេកទេសព័ត៌មានវិទ្យា មានភារកិច្ចៈ

- រៀបចំ និងគ្រប់គ្រងបណ្តាញព័ត៌មានវិទ្យា និងគេហទំព័ររបស់ក្រសួង
- ផ្សព្វផ្សាយទិន្នន័យ និងស្ថិតិពាណិជ្ជកម្មលើគេហទំព័រ
- ស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកទេសព័ត៌មានវិទ្យា
- ទទួលបន្ទុកជាមជ្ឈមណ្ឌលព័ត៌មានវិទ្យារបស់ក្រសួង
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៨** :

ការិយាល័យព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មាន មានភារកិច្ចៈ

- បោះពុម្ពផ្សាយព្រឹត្តិបត្ររបស់ក្រសួង
- ផ្សព្វផ្សាយទិន្នន័យស្ថិតិពាណិជ្ជកម្មស្តីពី ស្ថានភាពនៃការវិវត្តលើផ្នែកពាណិជ្ជកម្មក្នុង និងក្រៅប្រទេស

- រៀបចំធ្វើសន្ទស្សន៍ថ្លៃទំនិញចាំបាច់សំខាន់ៗ និងធ្វើស្ថិតិពាណិជ្ជកម្ម
- រៀបចំស្ថិតិប្រចាំថ្ងៃ សប្តាហ៍ ខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំជូនក្រសួង
- ធ្វើសេវាផ្តល់ព័ត៌មានទាក់ទងនឹងស្ថិតិពាណិជ្ជកម្មកម្ពុជា និងពិភពលោក
- ទទួលផ្សាយពាណិជ្ជកម្មលើគេហទំព័រ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ ៩** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៩
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធ នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

- ប្រធាននាយកដ្ឋាន
  - អនុប្រធាននាយកដ្ឋាន
    - ការិ.ផែនការពាណិជ្ជកម្ម
    - ការិ.រដ្ឋបាលទូទៅ
    - ការិ.សរុបស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
    - ការិ.បច្ចេកទេសព័ត៌មានវិទ្យា
    - ការិ.ព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មាន